ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៦ សសរ

# សារលិខិត
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
# នៃព្រះរាជាណាចក្រកម្ពុជា
# ផ្ញើជូន
# ជនរួមជាតិកម្ពុជាក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ
# ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

-សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ

-សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ជាទីមេត្រី

-បងប្អូនជនរួមជាតិ ដែលកំពុងរស់នៅក្នុងនិងក្រៅប្រទេស ជាទីស្នេហា

ទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមចូលរួមអំណរសាទរក្នុងទិវាបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ដែលប្រព្រឹត្តទៅនាថ្ងៃសៅរ៍ ១៤រោច ខែចេត្រ ថ្ងៃអាទិត្យ ១កើត និងថ្ងៃចន្ទ ២កើត ខែពិសាខ ត្រូវនឹងថ្ងៃទី១៤ ទី១៥ និងថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១៨ ជាមួយបងប្អូនជនរួមជាតិទាំងអស់ដែលកំពុងរស់នៅក្នុង និងក្រៅប្រទេស ប្រកបដោយក្តីសោមនស្សរីករាយ សិរីសួស្តី និងជ័យមង្គលដ៏ឧត្តុង្គឧត្តមក្នុងក្រុមគ្រួសារ និងសង្គមជាតិទាំងមូល។

ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ឆ្នាំនេះ បានប្រព្រឹត្តទៅជិតពេលបញ្ចប់នៃការអនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥នៃរដ្ឋសភា និងនៅក្នុងបរិការណ៍ដែលព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ នៃរដ្ឋសភា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យទី២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខស្របតាមកាលកំណត់ដែលបានចែងនៅក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ឆ្នាំចាស់ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ បានកន្លងទៅ ដោយផ្លាស់ជំនួសវិញនូវឆ្នាំថ្មី ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ជាមួយសេចក្តីសង្ឃឹមនិងភាពជឿជាក់ថា ព្រះរាជាណាចក្រកម្ពុជានឹងទទួលបាននូវការអភិវឌ្ឍថ្មីៗថែមទៀត ក្នុងបរិបទដែលកម្ពុជានៅតែរក្សាបាននូវសន្តិសុខ សុវត្ថិភាព និងសន្តិភាពពេញលេញនៅទូទាំងផ្ទៃប្រទេស។

កាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ ព្រះរាជាណាចក្រកម្ពុជា តាមរយៈគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ហើយការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នា២០១៨ បានដំណើរការដោយសេរី ត្រឹមត្រូវ យុត្តិធម៌ តម្លាភាព និងក្នុងបរិយាកាសស្ថិរភាពនយោបាយ។

ក្នុងឆ្នាំកន្លងទៅ ទោះបីកម្ពុជាបានប្រឈមនឹងឧបសគ្គគ្រប់បែបយ៉ាងទាំងក្នុង និងក្រៅប្រទេសក៏ដោយ ក៏ជឿនការពារជាតិរបស់ប្រជាជន និងជឿនសន្តិសុខជាតិ ត្រូវបានពង្រឹងយ៉ាងរឹងមាំ ធានាដល់កិច្ចការពារបូរណភាពទឹកដី ការពារសន្តិសុខ ស្ថិរភាពនយោបាយ និងភាពសុខដុមមនានៃសង្គមជាតិទាំងមូល ជាពិសេសឧបាយកលបដិវត្តន៍ពណ៌របស់គណបក្សប្រឆាំងដែលឃុបឃិតជាមួយបរទេស ប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ក៏ត្រូវបានទប់ស្កាត់ដោយជោគជ័យ តាមរយៈវិធានការច្បាប់ដ៏មុឺងម៉ាត់ ហើយក៏ជាឆ្នាំដែលបដិវត្តន៍ពណ៌ត្រូវទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរនៅកម្ពុជាផងដែរ។ ជាលទ្ធផល កម្ពុជារក្សាបាននូវសុខសន្តិភាព ឯករាជ្យ និងអធិបតេយ្យភាពរបស់ខ្លួន ព្រមទាំងបញ្ចៀសបាននូវគ្រោះមហន្តរាយជាថ្មីសម្រាប់ពលរដ្ឋកម្ពុជា ដែលកំពុងចូលរួមយ៉ាងសស្រាក់សស្រាំក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងកិច្ចអភិវឌ្ឍន៍ប្រទេសជាតិ។

ឈរលើមូលដ្ឋានដែលប្រទេសជាតិមានសន្តិសុខ និងសន្តិភាពពេញលេញនេះ ក្នុងឆ្នាំ២០១៧កន្លងទៅ តាមការប៉ាន់ស្មាន សេដ្ឋកិច្ចកម្ពុជាអាចសម្រេចបានកំណើន **៦,៩%**។ កំណើនដ៏រឹងមាំនេះ ត្រូវបានឆ្លុះបញ្ចាំង តាមរយៈការរីកចម្រើននៃវិស័យឧស្សាហកម្ម កម្មន្តសាល សំណង់ កសិកម្ម និងសេវាកម្ម ដូចជា ទេសចរណ៍ និងអចលនទ្រព្យជាដើម។ គួរកត់សម្គាល់ថា កម្ពុជាកំពុងតែផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសដែលពឹងផ្អែកលើវិស័យឧស្សាហកម្ម និងសេវាកម្ម។ កម្ពុជាបានអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រកបដោយភាពប្រុងប្រយ័ត្ន និងធ្វើឲ្យសេដ្ឋកិច្ចមានស្ថិរភាព ហើយបានជំរុញនិងលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ច ភាពប្រកួតប្រជែង ព្រមទាំងការផលិត និងការប្រើប្រាស់ផលិតផលទំនិញក្នុងស្រុក។ អត្រាប្តូរប្រាក់មានស្ថិរភាព អត្រាអតិផរណាស្ថិតក្នុងកម្រិតទាប និងអាចគ្រប់គ្រងបាន ទុនបម្រុងអន្តរជាតិបានកើនជារៀងរាល់ឆ្នាំ អាស្រ័យដោយវិនិយោគផ្ទាល់ពីបរទេសមានកំណើនល្អ និងតុល្យភាពជញ្ជីងទូទាត់ក៏មានភាពកាន់តែប្រសើរឡើងដែរ។ កម្រិតជីវភាពរបស់ប្រជាជនកាន់តែមានភាពល្អប្រសើរ ដែលបង្ហាញឲ្យឃើញតាមរយៈសូចនាករសង្គម ជាពិសេសការកើនឡើងនៃផលិតផលក្នុងស្រុកសរុប (ផសស)ជាមធ្យមសម្រាប់មនុស្សម្នាក់ពី **១ ០៤២ដុល្លារអាមេរិក** ក្នុងឆ្នាំ២០១៣ ដល់ប្រមាណ **១ ៤៣៥ដុល្លារអាមេរិក** ក្នុងឆ្នាំ២០១៧។ អត្រាភាពក្រីក្រមានការធ្លាក់ចុះយ៉ាងខ្លាំងពី **៥៣,៥%** ក្នុងឆ្នាំ២០០៤ មកត្រឹម **១៣,៥%** ក្នុងឆ្នាំ២០១៤ និងបន្តធ្លាក់ចុះថែមទៀតនៅឆ្នាំ២០១៧នេះ ហើយគម្លាតនៃប្រាក់ចំណូលរបស់ប្រជាជន ក៏មានការធ្លាក់ចុះជាលំដាប់ផងដែរ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បានរៀបចំបង្កើនប្រាក់ចំណូលជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឲ្យទទួលបាននូវប្រាក់បៀវត្សកាន់តែខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំ ស្របតាមគោលដៅជាង **១លានរៀល** នៅឆ្នាំ២០១៨នេះ។

ក្នុងឆ្នាំសិក្សា ២០១៧-២០១៨នេះ កុមារអាយុក្រោម៥ឆ្នាំ បានទទួលសេវាអប់រំគ្រប់រូបភាពមានជាង **៤សែននាក់** ហើយកុមារអាយុ៥ឆ្នាំ បានទទួលសេវាអប់រំតាមគ្រប់រូបភាពចំនួនជាង **២សែននាក់** សិស្សបឋមសិក្សា សាធារណៈមានជាង **២លាននាក់** សិស្សមធ្យមសិក្សាបឋមភូមិមានជាង **៦សែននាក់** និងសិស្សមធ្យមសិក្សា ទុតិយភូមិមានជាង **៣សែននាក់។** និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររងមានជាង **២ម៉ឺននាក់** និស្សិតកំពុង សិក្សាថ្នាក់បរិញ្ញាបត្រមានជាង **១សែន៦ម៉ឺននាក់** និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ

ជាន់ខ្ពស់មានជាង **២ម៉ឺននាក់** និងថ្នាក់បណ្ឌិតមានជាង **១ពាន់នាក់**។ ទន្ទឹមនេះ ក៏មានថ្នាក់បណ្តុះបណ្តាលជំនាញបច្ចេកទេសនានា ស្របតាមការអភិវឌ្ឍរីកចម្រើននៃដំណាក់កាលសាកលភាវូបនីយកម្ម នេះទៀតផង។

ក្នុងឆ្នាំកន្លងទៅ រាជរដ្ឋាភិបាលសម្រេចបានការងារធំៗជាច្រើនវិស័យ ក្នុងនោះការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន ត្រូវបានបន្តអនុវត្តជាប់ជាប្រចាំស្របតាមការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីបម្រើដល់វិស័យដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋ។ រហូតមកដល់បច្ចុប្បន្ន សមិទ្ធផលជាច្រើនក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានរាជរដ្ឋាភិបាលសម្រេចបាន ក្នុងនោះមាន៖ ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវលំជនបទ ស្ពានឆ្លងកាត់ទន្លេ ស្ពានអាកាសក្នុងរាជធានីភ្នំពេញ។ល។ ជាក់ស្តែង នៅដើមឆ្នាំ២០១៨នេះ ក្នុងរាជធានីភ្នំពេញ រាជរដ្ឋាភិបាលនឹងដាក់ឲ្យដំណើរការនូវស្ពានអាកាសថ្មីមួយទៀតនៅស្តុបផ្សារដើមហុយ លើមហាវិថីសហព័ន្ធរុស្ស៊ី និងស្ពានបាឡេឆ្លងកាត់ទន្លេសាបពីទីលានសួនប្រជាធិបតេយ្យផ្លូវជាតិលេខ៥ ទៅកាន់តំបន់ជ្រោយចង្វា ដែលមានប្រវែងជាង **៥០០ម៉ែត្រ** ព្រមទាំងស្ពានបេតុងកោះប៉ែន ដែលមានប្រវែង **៧៧៩ម៉ែត្រ** ភ្ជាប់ទឹកដីស្រុកកំពង់សៀមមកកាន់ក្រុងកំពង់ចាម ដែលស្ថាបនាឡើងដោយកូនខ្មែរសុទ្ធសាធ និងចំណាយថវិការបស់រាជរដ្ឋាភិបាលជាង **១៣លានដុល្លារអាមេរិក** ដើម្បីសម្រួលដល់ការកកស្ទះចរាចរណ៍ ការដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋ។ ក្នុងគោលបំណងនេះដែរ រាជរដ្ឋាភិបាលក៏បានសម្រេចដាក់ឲ្យដំណើរការនូវការធ្វើដំណើរតាមរថភ្លើងពីស្ថានីយរថភ្លើងក្នុងរាជធានីភ្នំពេញ ឆ្ពោះទៅកាន់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងការធ្វើដំណើរតាមផ្លូវទឹកចេញពីតំបន់ព្រែកព្នៅ រាជធានីភ្នំពេញ ឆ្ពោះទៅកាន់ក្រុងតាខ្មៅ ខេត្តកណ្តាល ដោយឆ្លងកាត់កំពង់ផែចំនួន **៩កន្លែង** សំដៅកាត់បន្ថយការកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញផងដែរ។

ក្នុងឆ្នាំរកា នព្វស័ក ព.ស.២៥៦១ កន្លងទៅនេះដែរ ដោយសារការអភិវឌ្ឍវិស័យធារាសាស្ត្រតូចធំគួបផ្សំនិងអាកាសធាតុមានលក្ខណៈអំណោយផលល្អសម្រាប់ការបង្កបង្កើនផលដំណាំស្រូវនៅទូទាំងព្រះរាជាណាចក្រកម្ពុជា បានធ្វើឲ្យបរិមាណផលិតផល ស្រូវរដូវវស្សានិងស្រូវរដូវប្រាំង សម្រេចបានប្រមាណជិត **១០លានតោន** កើនឡើងជាងផលិតផលស្រូវរដូវវស្សា និងស្រូវរដូវប្រាំងក្នុងឆ្នាំវក អដ្ឋស័ក ព.ស.២៥៦០ ប្រមាណ **៤,៥០%** និងសល់ស្រូវជាង **៥លានតោន** គិតជាអង្ករប្រមាណជាង **៣លានតោន** សម្រាប់បម្រើការនាំចេញ។ រីឯការនាំចេញអង្ករទៅទីផ្សារបរទេសបានជាង **០,៦០លានតោន** កើនជាងឆ្នាំមុនប្រមាណ**១៨%**។

ចំពោះវិស័យថាមពលអគ្គិសនីវិញ នៅឆ្នាំ២០១៧នេះ បរិមាណផ្គត់ផ្គង់ដោយវារីអគ្គិសនី និងរោងចក្រអគ្គិសនីដុតធ្យូងថ្ម ដែលជាប្រភពថាមពលផ្ទាល់របស់កម្ពុជាដល់តម្រូវការប្រើប្រាស់សម្រេចបាន**៨ពាន់លាន**គីឡូវ៉ាត់ម៉ោង បានកើនឡើងចំនួនប្រមាណ **១១%** បើប្រៀបធៀបនឹងឆ្នាំ២០១៦។ ការតភ្ជាប់ខ្សែបណ្តាញចរន្តឲ្យដល់ប្រជាពលរដ្ឋជាអ្នកប្រើប្រាស់ថាមពលអគ្គិសនីរហូតមកដល់ឆ្នាំ២០១៧នេះ ចំពោះគេហដ្ឋានប្រជាពលរដ្ឋសុទ្ធសាធ បានកើនដល់ប្រមាណ **២,៤១លានខ្នងផ្ទះ** ត្រូវជាប្រមាណ **៧១%** នៃចំនួនផ្ទះសរុបប្រមាណ **៣,៣៨លានខ្នង** និងគ្របដណ្តប់ដល់ភូមិប្រមាណ **៨១%** នៃចំនួនភូមិសរុប **១៤ ៣៦៨ភូមិ** នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

រហូតមកដល់បច្ចុប្បន្ន នៅព្រះរាជាណាចក្រកម្ពុជា វិស័យឧស្សាហកម្ម និងសិប្បកម្មបានរីកលូតលាស់ជាបន្តបន្ទាប់ ដែលក្នុងនេះ មានរោងចក្រសរុបចំនួនជាង **១ ៥០០រោងចក្រ** ដែលភាគច្រើនជារោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងមានឧស្សាហកម្មមធ្យម តូច និងសិប្បកម្មជាង **៣៩ពាន់មូលដ្ឋាន** ហើយដែលបានស្រូបកម្លាំងពលករសរុបប្រមាណជាង **១លាននាក់**។ ស្របនឹងការរីកចម្រើនវិស័យឧស្សាហកម្មនិង

សិប្បកម្ម រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ចំពោះកម្មករ និយោជិត ដែលកំពុងបម្រើការងារក្នុងវិស័យឯកជន ដោយបានសម្រេចដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករ និយោជិត ផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងកើនឡើងដល់ **១៧០ដុល្លារអាមេរិក** នៅឆ្នាំ២០១៨ ដោយមិនទាន់គិតទៅដល់ការទទួលបាននូវអត្ថប្រយោជន៍ផ្សេងៗទៀត ពីការអនុវត្តគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានគិតគូរ និងដោះស្រាយជូនបងប្អូននិយោជិត កម្មករ កម្មការិនី នូវអត្ថប្រយោជន៍ជាច្រើនទៀតដូចជាការពិនិត្យសុខភាព ការព្យាបាលជំងឺដោយមិនគិតថ្លៃនៅតាមមន្ទីរពេទ្យរបស់រដ្ឋ និងការធ្វើដំណើរតាមរថយន្តក្រុងសាធារណៈមិនគិតថ្លៃផងដែរ។

ស្របពេលជាមួយនឹងការរីកលូតលាស់នៃវិស័យសំណង់ជាអាទិ៍៖ អគារស្នាក់នៅរួម បុរី សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាននេះ ក៏មានអគារខ្ពស់ៗ ចាប់ពី៥ជាន់ ទៅ៤០ជាន់ឡើង ជិត១ពាន់ទីតាំង នៅក្នុងរាជធានីភ្នំពេញ និងតាមខេត្តនានាផងដែរ។ ភ្ញៀវទេសចរអន្តរជាតិក៏បានចូលមកព្រះរាជាណាចក្រកម្ពុជាមានចំនួនប្រមាណជាង **៥លាន៦សែននាក់** កើនឡើងប្រមាណ **១១,៦%** បើធៀបនឹងឆ្នាំ២០១៦ បានបង្កើតការងារដោយផ្ទាល់ដល់ប្រជាពលរដ្ឋកម្ពុជាមានប្រមាណ **៦២ម៉ឺននាក់** និងដោយប្រយោលប្រមាណជាង **១លាននាក់**។ ចំណូលពីវិស័យទេសចរណ៍បានកើនឡើងដល់ជាង **៣ ៨០០លានដុល្លារអាមេរិក** មានការកើន **១៧%** ហើយចំណូលពីការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គរមានប្រមាណ **១០១លានដុល្លារអាមេរិក** ដែលមានភ្ញៀវទេសចរអន្តរជាតិចូលទស្សនាប្រមាណ **២,៥លាននាក់** កើន **១១,៨២%** បើធៀបនឹងឆ្នាំ២០១៦។ នេះសបញ្ជាក់ឲ្យឃើញពីការរក្សាបាននូវសន្តិសុខ សុវត្ថិភាព និងសន្តិភាពនៅទូទាំងប្រទេសពីសំណាក់វិធានការច្បាប់ដ៏ម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាល។

ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បាន និងកំពុងជួយពលករកម្ពុជាដែលធ្វើការនៅបរទេសមានប្រមាណជាង **១លាននាក់** ដើម្បីធានានូវផលប្រយោជន៍ស្របច្បាប់ មុខជំនាញ បច្ចេកទេស ដូចជានៅប្រទេសថៃ កូរ៉េ ម៉ាឡេស៊ី ជប៉ុន សិង្ហបុរី និងហុងកុង។

ចំពោះការងារការបរទេសវិញ រាជរដ្ឋាភិបាល បានខិតខំបំពេញបេសកកម្មការទូតនៅលើឆាកអន្តរជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិលើគ្រប់វិស័យ ដោយទទួលបាននូវលទ្ធផលប្រកបដោយផ្លែផ្កា ជាអាទិ៍កិច្ចប្រជុំកំពូលពិសេសអាស៊ាន-អូស្ត្រាលី ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១៦ដល់ថ្ងៃទី១៨ខែមីនា ឆ្នាំ២០១៨ នៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលីកន្លងទៅថ្មីៗនេះ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានចូលរួមចំណែកបញ្ជូនកងយោធពលខេមរភូមិន្ទជាបន្តបន្ទាប់ទៅចូលរួមបំពេញបេសកកម្មក្រោមឆ័ត្រអង្គការសហប្រជាជាតិនៅសាធារណរដ្ឋស៊ូដង់ខាងត្បូង សាធារណរដ្ឋស៊ូដង់ សាធារណរដ្ឋម៉ាលី សាធារណរដ្ឋសាយប្រឹស សាធារណរដ្ឋអាហ្វ្រិកកណ្តាល និងសាធារណរដ្ឋលីបង់ ដែលមកដល់បច្ចុប្បន្នមានចំនួន **៣ ៥៧១នាក់** ក្នុងនោះស្រី **១៩៦នាក់**។

**សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ជាទីមេត្រី បងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា**

រាល់សមិទ្ធផលដែលរាជរដ្ឋាភិបាលសម្រេចបានកន្លងទៅនេះ គឺអាស្រ័យដោយមានការដឹកនាំខាងនយោបាយត្រឹមត្រូវ ប្រកបដោយឆន្ទៈមោះមុត មានការចូលរួមគាំទ្រពីសមាជិក សមាជិកានៃស្ថាប័ននីតិប្បញ្ញត្តិ សមាជិក សមាជិការាជរដ្ឋាភិបាល មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន និងការគាំទ្រយ៉ាងពេញទំហឹងពីប្រជាពលរដ្ឋទូទាំងប្រទេស ព្រមជា

មួយនេះដែរ ក៏មានការជួយឧបត្ថម្ភគាំទ្រដោយចិត្តស្មោះសរពីបណ្តាប្រទេសជាមិត្ត ដៃគូអភិវឌ្ឍន៍និងសហគមន៍អន្តរជាតិផងដែរ។

ឆ្លៀតក្នុងឱកាសនេះដែរ ទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលមានសិទ្ធិបោះឆ្នោត ហើយដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតរួចហើយ សូមអញ្ជើញទៅចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅ**ថ្ងៃអាទិត្យទី២៩ ខែកក្កដា ឆ្នាំ២០១៨** ខាងមុខឲ្យបានគ្រប់ៗគ្នាកុំបីខាន ដើម្បីអនុវត្តសិទ្ធិពលរដ្ឋ ក្នុងឋានៈជាម្ចាស់ជោគវាសនានៃប្រទេសរបស់ខ្លួន។

សម្រាប់ឆ្នាំថ្មី ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានឹងខិតខំពុះពារគ្រប់បែបយ៉ាងជាបន្តទៀត ដើម្បីបន្តថែរក្សាការពារសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ឲ្យបានកាន់តែរឹងមាំ ការពាររដ្ឋធម្មនុញ្ញ ការពាររបបរាជានិយម ស្របតាមបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ និងការពាររាល់សមិទ្ធផលដែលរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋទាំងមូលសម្រេចបានកន្លងទៅ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងបន្តការធ្វើកំណែទម្រង់រដ្ឋដ៏ស៊ីជម្រៅតាមអភិក្រម "**ឆ្លុះកញ្ចក់ ងូតទឹក ដុះក្អែល ព្យាបាល និងវះកាត់**" ក្នុងនោះមានការពង្រឹងអភិបាលកិច្ចល្អ តាមរយៈការពង្រឹងស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ ការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការអភិវឌ្ឍធនធានមនុស្ស កែលម្អប្រព័ន្ធអប់រំឲ្យកាន់តែមានគុណភាពខ្ពស់ ការលើកកម្ពស់ប្រព័ន្ធការពារសង្គម ការលើកកម្ពស់គុណភាពសេវាសុខាភិបាល និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សំណង់ ផ្លូវ ស្ពាន ធារាសាស្ត្រ ព្រមទាំងបង្កើនប្រភពថាមពលអគ្គិសនី ដើម្បីបន្តការអភិវឌ្ឍវិស័យឧស្សាហកម្ម សិប្បកម្ម សេវាកម្មដឹកជញ្ជូន ពាណិជ្ជកម្ម ទេសចរណ៍ និងវិស័យកសិកម្ម ឲ្យកាន់តែរីកចម្រើនថែមទៀត។

**សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ជាទីមេត្រី បងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា**

ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ នេះ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមទូលបង្គំជាខ្ញុំ ព្រមទាំងមន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងបងប្អូនជនរួមជាតិទាំងអស់ ទូលបង្គំជាខ្ញុំ សូមលំឱនកាយវាចាចិត្ត គោរពបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបីវត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាឆ្នាំថ្មី ព្រះនាម **មហោធរៈទេវី** សូមប្រោះព្រំសព្ទសាធុការពរ បវរមហាប្រសើរ ចំពោះព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល សូមព្រះអង្គមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ព្រះរាជសុខភាពបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់នៅក្នុងព្រះបរមសិរីរាជសម្បត្តិ ជាម្លប់ដ៏ត្រជាក់នៃប្រជាពលរដ្ឋខ្មែរ ជាកូន ជាចៅ ចៅទួត ជានិច្ចនិរន្តរ៍តរៀងទៅ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះដែរ ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមទូលបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយនិងប្រគេនព្រះពរចំពោះសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ និងព្រះសង្ឃគ្រប់ព្រះអង្គ សូមមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា មានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់ជាម្លប់របស់

ពុទ្ធបរិស័ទក្នុងព្រះរាជាណាចក្រកម្ពុជាជានិច្ចនិរន្តរ៍តរៀងទៅ និងសូមជូនពរដល់ជនរួមជាតិខ្មែរគ្រប់រូបដែលកំពុងរស់នៅក្នុង និងក្រៅប្រទេស មន្ត្រីរាជការ នាយទាហាន ពលទាហាននៃកងយោធពលខេមរភូមិន្ទ ដែលបាននិងកំពុងបំពេញភារកិច្ចការពារអធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងកំពុងបំពេញបេសកកម្មរក្សាសន្តិភាព និងមនុស្សធម៌នៅក្រៅប្រទេស នាយនគរបាល ពលនគរបាលដែលបាននិងកំពុងរួមចំណែកការពារបូរណភាពទឹកដី និងថែរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៃមាតុភូមិ ក្មួយៗសិស្សានុសិស្ស និស្សិត យុវជន យុវនារី កម្មករ និយោជិត ធុរជន និងវិនិយោគិនដែលកំពុងប្រកបធុរកិច្ចនៅលើទឹកដីកម្ពុជា សូមទទួលបាននូវភាពជោគជ័យសិរីសួស្តី ជ័យមង្គល និងវិបុលសុខជាដរាបតរៀងទៅ។

សូមទេវតាឆ្នាំថ្មី ព្រះនាម **មហោធរៈទេវី** ជួយអភិបាលគ្រប់គ្រង ជួយបីបាច់ថែរក្សាគាំពារ និងប្រសិទ្ធពរជ័យដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ឲ្យមានសមានចិត្តជាកុសល យោគយល់គ្នា រួបរួមសាមគ្គីគ្នាជាមហាគ្រួសារតែមួយនៅលើទឹកដីមាតុភូមិអង្គរជាទីស្នេហា ដោយសេចក្តីសុខក្សេមក្សាន្ត និងប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ តរៀងទៅ។

*សូមអរព្រះគុណនិងអរគុណ!*

ថ្ងៃអង្គារ ៣រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែមេសា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**